# អដ្ឋិកមក្តកថាសង្ខេប



## ព្រះវិហារថ្មីវត្តអារញ្ញិការាម

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ប្រវត្តិសង្ខេប វត្តអារញ្ញិការាម

## I. អំពីទីតាំង

វត្តអារញ្ញិការាម ហៅវត្តអារញ្ញ ស្ថិតនៅក្នុងភូមិស្រែព្រីង ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

តាមសេចក្តីដំណាលរបស់ចាស់ព្រឹទ្ធាចារ្យ មានលោកតា ឧបាសក ឃុត អេង និង ឧបាសិកា សុខ ហៀន ជាដើមបានឱ្យដឹងថា វត្តនេះពីដើមតាំងនៅខាងលិចផ្លូវជាតិលេខ ៥ ខាងក្រោយឆៀងទិសពាយ័ព្យបន្តិច នៃទីតាំងវត្តបច្ចុប្បន្ននេះ ។

វត្តចាស់នោះមានឈ្មោះថា វត្តពពាលខែ ហើយខាងមុខវត្តនេះមានអ្នកតាមួយហៅអ្នកតា ក្រហមក ។ សព្វថ្ងៃនៅមានគេគោរពបន់ស្រន់ខ្លះនៅឡើយ ។

ដោយដីវត្តចាស់នោះ ជាទីដីទំនាបខែវស្សាមានទឹកលិច ហើយផ្ទៃដីក៏តូចផង ព្រមទាំងសំណង់ផ្សេងៗដូចជា កុដិ សាលា ព្រះវិហារជាដើម ក៏មិនទាន់មានអ្វីជាសំខាន់ផង ពុទ្ធបរិស័ទមានព្រះគ្រូព្រះនាម គង់ និងអាចារ្យវត្តជាដើម បានឯកភាពគ្នាសុំការអនុញ្ញាតពីអាជ្ញាធរខេត្ត រុះរើវត្តចាស់នោះមកកសាងនៅកន្លែងសព្វថ្ងៃនេះ ។

ការរុះរើវត្តចាស់មកសាងវត្តថ្មីនេះ គឺនៅ ព.ស ២៤៨៤ គ.ស ១៩៤១ ។

ឯកន្លែងសាងវត្តសព្វថ្ងៃនេះ កាលពី៥០ឆ្នាំកន្លងទៅហើយជាទីរហោឋានព្រៃព្រឹក្សាមានដើមឈើធំ តូច ដុះជាច្រើនដូចជា គគីរ ក្រកោះ ត្នោត ត្បែង



ពពេល ពពាលខែ ត្រាច ធ្នង់ ធ្លក ឈើត្រាវ ។ល។ និងឫស្សីព្រៃយ៉ាងក្រាស់ ហើយជាព្រៃស្មសានដែលគេតែងតែយកខ្មោចមកកប់នៅទីនោះ ។ ដោយហេតុនោះហើយបានជាវត្តនេះមានឈ្មោះថា អារញ្ញិការាមឬ វត្តអារញ្ញ ។ វត្តនេះមានផ្ទៃដីធំទូលាយខាងលិចទល់ផ្លូវជាតិលេខ ៥ ខាងកើតទល់និងវាលស្រែ ។

ប៉ុន្តែនៅក្នុងសម័យកាលនៃព្រះគ្រូ សុខ ហាប់ ជាចៅអធិការព្រះអង្គបានបែងចែកបួយចំណែកខាងក្រោយវត្តសំរាប់កសាងសាលារៀន ដោយមានរូបព្រះអង្គផ្ទាល់ ជាអ្នកខ្វល់ខ្វាយក្នុងការកសាងសាលារៀននេះ ដែលសព្វថ្ងៃសាលានេះហៅថា សាលាបឋមសិក្សាអារញ្ញ ។

រីឯដីទំនាបមុខព្រះវិហារ ពីដើមជាដីស្រែរបស់លោកតា នុយ យាយចៅ ដែលជាញោមបង្កើតរបស់ព្រះគ្រូ សុខ ហាប់ គាត់បានវេរដីនោះថ្វាយសង្ឃទុកជាសម្បត្តិរបស់វត្ត ចាប់តាំងពីវត្តមកតាំងនៅក្នុងទីនេះ ។

ឯផ្ទៃដីទាំងមូលនៃវត្តនេះ សព្វថ្ងៃមានទំហំត្រឹមតែ២៨៥៩៥ម៉ែត្រក្រឡាប៉ុណ្ណោះ ។

## II អំពីការកសាងក្នុងតំណាក់កាល ចៅអធិការនីមួយៗ

១-ព្រះគ្រូព្រះនាម គង់បានរៀបចំទីនេះធ្វើជាវត្តហើយបានសាងសាឡា ១ កុដិឈើតូចៗ ៣ខ្នង អណ្តូងទឹក១ ព្រមទាំងមានបង្គោលក្រាក់ព័ទ្ធជុំវិញវត្ត ។

២-ព្រះគ្រូ សុខ ហាប់ បានកសាងព្រះវិហារ ១ជាន់ កុដិថ្ម ១ខ្នង កុដិឈើ៣ខ្នង ឧបដ្ឋានសាលា១ខ្នង សាលាពុទ្ធិកបឋមសិក្សា១ខ្នង សាលាគរុកោសល្យអនុវត្តន៍១ខ្នង សាលារៀន២ខ្នង កុដិថេរសំរាប់ព្រះសង្ឃ

គង់នៅ១ខ្នង បង្គន់២ អណ្តូងទឹក៣ និង ដាំដើមដូងបាន២៥ដើម ស្វាយ ៣ដើម ទឹកដោះគោ៥ដើម ចាមរី ៥ដើម ។ ឯការសិក្សាមានទាំងផ្លូវលោក ទាំងផ្លូវធម៌ ។

ជាអកុសលនៅឆ្នាំ ១៩៧០ សង្គ្រាមក្នុងស្រុកបានកើតឡើងហើយនៅឆ្នាំ ១៩៧៥ ទាំងព្រះសង្ឃទាំងគ្រហស្ថ ក្នុងវត្តនេះក៏ដូចជាទូទាំងប្រទេសកម្ពុជាត្រូវគេជំលៀសឱ្យទៅនៅព្រៃភ្នំ ជនបទដាច់ស្រយាល ។ ពេលនោះសមិទ្ធិទាំងឡាយ ទាំងព្រះគ្រូ សុខ ហាប់ ទាំងពុទ្ធបរិស័ទចំណុះវត្តក៏បានវិនិច្ឆធម្ម ស្លាប់បាត់បង់ជីវិតអស់ជាច្រើន ។ នៅឆ្នាំ ១៩៧៩ អ្នកនៅរស់ទាំងប៉ុន្មាន ក៏បានវិលត្រឡប់មកកាន់ភូមិកំណើតវិញ ហើយក៏ចាប់ផ្តើមកសាងវត្តនេះបន្ត ។

៣-ព្រះគ្រូ សុខ យ៉េម ជាបព្វជិតបួសថ្មី ក្រោយថ្ងៃ ៧មករា ឆ្នាំ ១៩៧៩ លោកបានមកគង់រៀបចំវត្តនេះជាដំបូង ។ ប៉ុន្តែមិនបានកសាងអ្វីទេគ្រាន់តែបានរៀបចំបោសច្រាស់ សំអាតកំទេចកំទី និង ជុសជុលកុដិខ្លះ ដែលនៅសល់តិចតួចប៉ុណ្ណោះ ។ លោកក៏ត្រូវគណសង្ឃនិង អាជ្ញាធរខេត្ត បានចាត់និមន្តឱ្យទៅធ្វើចៅអធិការនៅវត្តនិគ្រោធារាម ហៅជ្រៃបាក់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ឯណោះទៅ ។

៤- ព្រះគ្រូ ម៉ៅ ឡែ ព្រះអង្គត្រូវបានគណសង្ឃនិងអាជ្ញាធរខេត្ត និមន្តឱ្យមកគង់នៅធ្វើចៅអធិការវត្តនេះ ហើយបានទទួលឋានៈជាព្រះបាល័ដ្ឋគណខេត្ត ព្រមទាំងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រ របស់ខេត្តកំពង់ឆ្នាំងទាំងមូល និង ជាគ្រូខាងវិបស្សនាធុរៈផង ។



ព្រះអង្គបានដឹកនាំពុទ្ធបរិស័ទផ្តើមកសាងព្រះវិហារនេះបន្តពីព្រះគ្រូសុខ ហាប់ ដរាបដល់បានសម្រេចជាស្ថាពរព្រមទាំងបានសាងកុដិឈើ ៤ខ្នង កំពែងថ្មខាង មុខនិងខាងក្រោយវត្តហើយបានធ្វើឱ្យទីធ្លាវត្តអារាមនេះទាំងមូល មានសោភ័ណភាពសប្បាយឡើងវិញ ។

ចំពោះព្រះវិហារថ្មីនេះ បានចាប់ផ្តើមកសាងមកតាំងតែពី ព.ស ២៥១០ គ.ស ១៩៦៧ គឺតាំងតែពីសម័យកាល ព្រះគ្រូ សុខ ហាប់ ម្ល៉េះ តែចាប់ពីឆ្នាំ ១៩៧០រហូតដល់ឆ្នាំ ១៩៨៨ ត្រូវរាក់ខានមិនអាចធ្វើទៅបាន លុះមកដល់ឆ្នាំ ១៩៨៩ ទើបបានចាប់កសាងបន្ត ហើយបានសំរេចជាស្ថាពរ នៅក្នុងខែពិសាខ ឆ្នាំជូវ ព.ស ២៥៤០ គ.ស ១៩៩៦ ព្រមទាំងបានធ្វើបុណ្យសម្ពោធ ឆ្លងនិងបញ្ចុះខ័ណ្ឌសីមា នៅថ្ងៃ ១៥កើត ខែ ផល្គុណ ឆ្នាំ ថោះ ឯកស័ក ព.ស ២៥៤៣ ត្រូវនឹងថ្ងៃទី ១៩មិនា ឆ្នាំ ២០០០ ដោយសោមនស្សរីករាយក្រៃលែង ។

សូមឧទ្ទិសកុសលដ៏ធំធេងនេះ ប្រគេនព្រះតេជៈព្រះគុណ អតីតចៅអធិការវត្តអារញ្ញិការាមគ្រប់ព្រះអង្គព្រមទាំងបុព្វការីជនទាំងអស់ ដែលបានដឹកនាំនិងកសាងវត្តអារញ្ញិការាមនេះ សូមបានប្រកបដោយសុភមង្គល វិបុលសុខ សមតាមសេចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

**អ្នកស្រាវជ្រាវ**

គណៈកម្មការចាត់ចែងពិធីបុណ្យសម្ពោធ

ឆ្លងនិងបញ្ចុះខ័ណ្ឌសីមាវត្តអារញ្ញិការាម

## អដ្ឋង្គិកមគ្គកថាសង្ខេប

ពពពពព

វិសុទ្ធករុណាញាណំ ពុទ្ធំ សម្ពុទ្ធមង្គលំ

ធម្មំ សន្ទុម្ពសង្ខតំ វន្ទេ សង្ឃំ និរង្គណំ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គមាន ព្រះហឫទ័យ ប្រកបដោយព្រះមហាករុណាដល់សត្វលោកជាសាកល ។

សូមក្រាបថ្វាយបង្គំ ចំពោះព្រះសទ្ធម្មជាទីករមត្រជាក់ត្រៀបកាន្តជាគុណរំលត់នូវភ្លើងទុក្ខភ្លើងកិលេសដែលពុសពុក្នុងសកលលោក ជាធម៌ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សំដែងហើយ ។

សូមក្រាបថ្វាយបង្គំ ចំពោះព្រះសង្ឃជាម្ចាស់ដែលកើតដោយអរិយជាតិព្រោះព្រះសទ្ធម្ម ជាអ្នកមានព្យាយាមប្រតិបត្តិព្រះធម៌ដ៏បរិសុទ្ធមិនមានកិលេសដូចជាទីទួលក្នុងខន្ទសន្តានឡើយ ។

រតនត្តយតេជេន សុវត្ថិ ហោន្តុ សព្វទា ដោយអំណាចនៃព្រះរតនត្រ័យ សូមសវត្ថិមង្គលកើតមានដល់ពុទ្ធបរិស័ទសប្បុរសជនទូទៅអស់កាលជានិច្ចនិរន្តរ៍ ។

### តទនន្តរំ អដ្ឋង្គិកមគ្គំ ទេសេស្សាមិ

លំដាប់ពីបទនមស្ការនេះទៅ សូមលើកយកអដ្ឋង្គិកមគ្គមកសំដែងដោយសេចក្តីសង្ខេប ដូចខាងក្រោមនេះ :-

អដ្ឋង្គិកមគ្គ ផ្លូវប្រកបដោយអង្គប្រាំបីដែលនាំសត្វអ្នកប្រតិបត្តិដើរតាមទៅកាន់ទីរំលត់ទុក្ខ ឬហៅថា:-អរិយមគ្គ ផ្លូវដ៏ប្រសើរ ដែលនាំសត្វទៅកាន់



អមតមហានិព្វាន ។ ព្រះធម៌នេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់សំដែង នៅក្នុងបឋមទេសនា ដែលហៅថាព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុនាព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី ។

នៅក្នុងបឋមទេសនាគឺទេសនាជាដំបូងនោះ ព្រះសម្ពុទ្ធទ្រង់សំដែង អំពីអរិយ សច្ច ៤ ប្រការ គឺ :-

១- **ទុក្ខសច្ចៈ** ទុក្ខជាសេចក្តីពិត

២- **សមុទយសច្ចៈ** ហេតុដែលនាំឱ្យកើតទុក្ខជាសេចក្តីពិត

៣- **និរោធសច្ចៈ** ការរលត់ទុក្ខជាសេចក្តីពិត

៤- **មគ្គសច្ចៈ** មាគ៌ានាំទៅកាន់ទីរលត់ទុក្ខជាសេចក្តីពិត

មគ្គសច្ចជាអរិយសច្ចៈទី៤នេះហើយដែលហៅថា**អដ្ឋង្គិកមគ្គ** ឬ **អរិយមគ្គ**នេះឯង អដ្ឋង្គិកមគ្គ នេះជាផ្លូវកណ្តាលមិនស្ទាំពេកមិនឆ្វេងពេកឈ្មោះថាមជ្ឈិមាបដិបទា ។ មជ្ឈិមាបដិបទា នេះជាផ្លូវនាំសត្វឱ្យចេញផុតអំពីផ្លូវប្រតិបត្តិអបទាំងពីរគឺ :

១-**កាមសុខល្លិកានុយោគ** ផ្លូវស្តាំពេកជាផ្លូវនាំសត្វទៅកាន់សេចក្តីសុខដោយកាម ជាធម៌របស់អ្នកស្រុក ជាធម៌ថោកទាបមិនមែនជាធម៌របស់ព្រះអរិយបុគ្គល ។

២-**អត្តកិលមថានុយោគ** ផ្លូវឆ្វេងពេក ជាផ្លូវនាំសត្វទៅរកសេចក្តីទុក្ខដោយការធ្វើឱ្យលំបាកខ្លួនឥតប្រយោជន៍ ដូចជាការប្រព្រឹត្តតបៈយោគៈជាអំពើប្រកប ដោយទុក្ខលំបាក ជាធម៌មិនប្រសើរ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា :-

ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា  ភិក្ខុទាំងឡាយផ្លូវទាំងពីរនេះបព្វជិតមិនគួរសេពគប់ទេ ។

ព្រោះផ្លូវទាំងពីរប្រការនេះព្រះសម្ពុទ្ធទ្រង់បានប្រព្រឹត្តសាកល្បងមើលរួចមកហើយឃើញពិតថាឥតប្រយោជន៍ទើបព្រះអង្គលះបង់ចោលទៅ  ហើយទ្រង់រកឃើញផ្លូវកណ្តាល ដែលហៅថា  មជ្ឈិមាបដិបទា  ។ មជ្ឈិមាបដិបទានេះហើយដែលនាំឱ្យព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ  ទ្រង់ត្រាស់បញ្ជាក់ថាៈ-

**មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** = (ម្នាលភិក្ខុទាំងឡាយ)  មាគ៌ាកណ្តាលនេះនាំ តថាគតឱ្យបានត្រាស់ដឹង ធ្វើឱ្យកើតចក្ខុ  ធ្វើឱ្យកើតញាណ  ធ្វើឱ្យកើតការស្ងប់  ធ្វើឱ្យចាក់ធ្លុះនូវសច្ចធម៌ ធ្វើឱ្យត្រាស់ដឹង  ធ្វើឱ្យបានលុះព្រះនិព្វាន ។ មាគ៌ាដ៏ប្រសើរនេះមាន ៨ ប្រការគឺ :-

១‿សម្មាទិដ្ឋិ  ការយល់ឃើញត្រឹមត្រូវ ([illegible])

២‿សម្មាសង្កប្បៈ  ការត្រិះរិះត្រឹមត្រូវ (1)

៣‿សម្មាវាចា  ការពោលត្រឹមត្រូវ ([illegible])

៤‿សម្មាកម្មន្តៈ  ការងារត្រឹមត្រូវ ([illegible])

៥‿សម្មាអាជីវៈ  ការចិញ្ចឹមជីវិតត្រឹមត្រូវ ([illegible])

៦‿សម្មាវាយាមៈ ការព្យាយាមត្រឹមត្រូវ ([illegible])

៧‿សម្មាសតិ  ការរលឹកត្រឹមត្រូវ ([illegible])

៨‿សម្មាសមាធិ  ការតំកល់ចិត្តត្រឹមត្រូវ  ។ ([illegible])

(1) [illegible]



ព្រះពុទ្ធវចនៈ ទាំងអស់ដែល ព្រះ សព្វញ្ញុពុទ្ធ ទ្រង់ត្រាស់ សំដែង អស់ចិរៈវេលា៤៥ព្រះវស្សារួបមកគឺ នៅក្នុងមាគ៌ាដ៏ប្រសើរទាំង ៨ដែលហៅ អរិយមគ្គ ឬ អដ្ឋង្គិមគ្គ នេះឯង ។

ឯការប្រតិបត្តិតាមមាគ៌ាប្រកបដោយអង្គប្រាំបីប្រការនេះ  មិនមែនប្រតិបត្តិមួយម្តង១តាមលេខរៀងជាលំដាប់លំដោយនោះទេ  គឺត្រូវប្រតិបត្តិព្រមគ្នាតាមដែលអាចធ្វើទៅបាន  ព្រោះមាគ៌ានីមួយ១ ជាបច្ច័យទាក់ទង ទៅមាគ៌ាមួយទៀត  ។

មាគ៌ាទាំង៨ ប្រការ នេះ  រួបមាន៣ ពួកគឺ  :-

១- **សីលខន្ធ** ពួកសីលបានដល់  សម្មាវាចា  សម្មាកម្មន្តៈ  សម្មាអាជីវៈ  ។

២- **សមាធិខន្ធ**  ពួកសមាធិបានដល់  សម្មាវាយាមៈ  សម្មាសតិ សម្មាសមាធិ ។

៣- **បញ្ញាខន្ធ** ពួកបញ្ញា បានដល់  សម្មាទិដ្ឋិ សម្មាសង្កប្បៈ ។

សូមបញ្ជាក់តាមខ្លឹមសារពុទ្ធឱវាទដូចតទៅ :-

សីលខន្ធ  ពួកសីល  សីលនេះជា ខាងដើម នៃកុសលធម៌ ទាំងពួង ជា កាំជណ្តើរទី១  សំរាប់ឈានឡើងទៅកាន់ធម៌ ជាន់ខ្ពស់តាមលំដាប់  ជាគ្រឿងអាភរណៈ អលង្ការគ្រឿងស្លៀកពាក់សំរាប់លំអដល់កាយវាចា  ឱ្យបានសមរម្យដល់ភាពជាមនុស្ស  ប្លែកពីសត្វតិរច្ឆាន ។  ធម៌ នេះ ធ្វើឱ្យមនុស្ស  មានមេត្តា ករុណាដល់គ្នា និងគ្នា  ជាគុណធម៌ សាងសុខសន្តិភាព  សាងសាមគ្គីភក្តីភាព  សាងសេចក្តីស្រឡាញ់

ការស្មោះត្រង់ដល់គ្នានិងគ្នាចាប់តាំងពីគ្រួសារ ជាតិសាសនា រហូតដល់សង្គមមនុស្សលោក ទាំងមូល និង សព្វសត្វដែលមានជីវិតទាំងអស់ជាសាកល ។

ព្រះពុទ្ធទ្រង់ប្រទានឱវាទថា :- **អត្តសម្មាបណិធិ** =( កើតជាមនុស្ស ) ត្រូវសាងខ្លួនឱ្យបានល្អប្រសើរដោយធម៌ ២ យ៉ាង គឺ :-

**១-ករុណា** ជាធម៌សាងគុណសម្បត្តិខាង ផ្លូវចិត្តឱ្យចេះស្រឡាញ់រាប់អានគ្នាឱ្យមានអំណត់ខន្តី និង សេចក្តីសន្តោសគ្នា ទៅវិញទៅមក .។

**២-បញ្ញា** ជាធម៌សាងមនុស្សឱ្យបានការពន្លឺសវៃ ឱ្យមើលឃើញពិតទៅតាមសេចក្តីពិត "**យថា ភូតំ បជានាតិ**" ។

ធម៌នេះជាធម៌ធ្វើមនុស្សឱ្យមាន គុណ សម្បត្តិ ខាងចំណេះវិជ្ជា បានបញ្ញាញាណ ទូលំទូលាយ ។

មនុស្សណាខំប្រឹងប្រែងប្រតិបត្តិតែខាងធម៌ធ្វើឱ្យកើតករុណា សេចក្តីស្រឡាញ់រាប់អានគ្នាតែម្យ៉ាង មិននឹកនាប្រតិបត្តិធម៌ឱ្យកើតបញ្ញា និង វិជ្ជាអ្នកនោះនឹង ជាមនុស្ស មានចិត្តល្អតែល្ងង់ខ្លៅ អប្បឥត បញ្ញាមើល ទៅដូច ផ្កាមានពណ៌ស្រស់ល្អឥតមានក្លិនក្រអូប ។

មនុស្សណាខំប្រឹងប្រែងប្រតិបត្តិ តែខាងធម៌ធ្វើឱ្យកើត បញ្ញា និង វិជ្ជាតែម្យ៉ាង មិននឹកនាប្រតិបត្តិធម៌ដែលធ្វើឱ្យកើតសេចក្តីអាណិត ស្រឡាញ់ ចិត្តមេត្តាករុណាដល់គ្នាផងទេនោះ អ្នកនោះនឹងទៅជាមនុស្សមានបញ្ញាឈ្លាសវៃមានពន្លឺក្នុងចិត្ត តែជាមនុស្សរឹងរូសមានចិត្តកាចទ្រនង់យង់ឃ្នងមិនគិតដល់អ្នកដទៃចិត្តកាចឃោរឃៅ ដូចសត្វសាហាវ ។



ដូច្នេះ មនុស្សម្នាក់ៗ ត្រូវតែប្រតិបត្តិធម៌ទាំងពីរប្រការនេះ ឱ្យបានស្មើគ្នា ទើបសេចក្តីសុខចំរើនកើតឡើងបានហើយជាគុណប្រយោជន៍ល្អប្រសើរ ដូចជាផ្កាមានក្លិនក្រអូបផងមានពណ៌ស្រស់ល្អផង ជាគុណធម៌ធ្វើឱ្យបុគ្គលខ្លួនឯង សង្គមគ្រួសារ សង្គមជាតិ រហូតដល់សកលលោកបានចំរើនដុះដាលសុខសន្តិភាពជានិច្ចនិរន្តរ៍ ។ វិគុណធម៌ ២ប្រការពីបេត្តា "ចិត្តរាណើតរាស្សូរ" ករុណេក ការធ្វើឱ្យគេ រួចចាកទុក្ខបានសុខចំរើន " ជាធម៌ បានការទាក់ទងគ្នាទៅវិញទៅមក ។

ធម៌ ទាំងពីរនេះស្ថិតនៅក្នុងពួកសីល បានដល់សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈ ក្នុងបណ្តាអដ្ឋបត្តទាំង ៨ ។

- **សម្មាវាចា** "សំដីត្រឹមត្រូវ" បានដល់ការវៀរចាកវចីទុច្ចរិត៤យ៉ាងគឺ :-

**១- មុសាវាទា វេរមណី** វៀរពោលពាក្យមិនពិតគឺនិយាយតែពាក្យពិត ពាក្យដែលធ្វើឱ្យគេស្រឡាញ់រាប់អានមនុស្សលោកពេញចិត្តនិងពាក្យពិត ពាក្យពិតជាទីស្រឡាញ់របស់មនុស្សលោកទូទៅ។ អ្នកនិយាយពាក្យមិនពិតជាមនុស្សឥតខ្លឹមសារសាបរលាបប្រើការមិនបាន។ ពាក្យពិតជាពាក្យមានខ្លឹមសារជាពាក្យមិនស្លាប់ "**សច្ចំ វេ អមតំ វាចា**" ពាក្យពិតជាពាក្យធ្វើមនុស្សក្នុងសង្គមឱ្យបានការទុកចិត្តគ្នាទៅវិញទៅមក ជាធម៌សាងភក្តីភាពសេចក្តីស្មោះត្រង់ជំនឿស្មោះត្រង់ដល់គ្នានិងគ្នាដែលនាំឱ្យមានសេចក្តីសុខ ។

**២- បិសុណាយ វាចាយ វេរមណី** "វៀរពោលពាក្យស៊កសៀតញុះញង់" គឺនិយាយតែពាក្យដែលនាំឱ្យកើតសេចក្តីរីករាយ នាំឱ្យកើតសាមគ្គីធម៌ នាំឱ្យកើតមេត្តាចិត្តរវាងមនុស្សផងគ្នា។ មិននិយាយពាក្យដែលនាំឱ្យកើតចលាចល

ជម្លោះទាស់ទែងគ្នា ។ និយាយតែពាក្យដែលនាំឱ្យមានចិត្តសប្បុរស ឱ្យមានការយោគយល់គ្នា ចេះសន្តោសអត់អោនដល់គ្នានិងគ្នា ។ បើមនុស្សនិយាយតែពាក្យល្អមិនពោលពាក្យ ញុះញង់ បំបែកបំបាក់ សង្គ្រាម ជម្លោះ ពិតជាមិនអាចកើតមានក្នុងលោកនេះបានឡើយ លោកនេះនឹងមានសាមគ្គីសុខដុមរមនាជានិច្ចនិរន្តរ៍ ។

**៣_ ផរុសវាចា វេរមណី** "វៀរពោលពាក្យធ្វើឱ្យគេឈឺចាប់ដូចជាគេចាំងនិងដឹងឬកាប់និងប៉ូវថៅ " គឺពាក្យជេរប្រទេចជេរជាប ត្មិះដៀលបញ្ឈិតបញ្ឈៀងប្រមាថ មើលងាយធ្វើឱ្យគេឈឺចិត្តក្តៅក្រហាយ ។

ពេលណាដែលមានមនុស្សចូលចិត្តនិយាយពាក្យដូចដឹង ឬ ប៉ូវថៅនេះ ពេលនោះសីលធម៌ ត្រូវធ្លាក់ចុះថោកទាបមនុស្សក្លាយទៅជាសត្វតិរច្ឆាន លែងស្គាល់អ្វីដែលជាគុណប្រយោជន៍ ។

ដូច្នេះមនុស្សត្រូវនិយាយពាក្យផ្អែមល្ហែមគួរជាទីពេញចិត្តនៃមនុស្សទូទៅ ។ ពាក្យពីរោះហ្នឹងទុក ដូចជាទឹកបន្សាបផ្សាមិត្តភាពធ្វើមនុស្ស លោកឱ្យ បានជាមិត្តដ៏ល្អដល់គ្នានិងគ្នា ។ ហើយពាក្យពិរោះប្រកបដោយចិត្តមេត្តាករុណានេះ ជាគុណធម៌បំបាត់នូវពៀរ វេរា និង អារិភាព ក្នុងសង្គមមនុស្សលោក ។

**៤_សម្ផប្បលាបា វេរមណី** "វៀរពោលពាក្យឡេះឡោះឥតបានការ" ពាក្យឥតខ្លឹមសារនេះនាំឱ្យខាតប្រយោជន៍ទូទៅ ទាំងប្រយោជន៍ខ្លួនទាំងប្រយោជន៍អ្នកដទៃ ។ ដូច្នេះត្រូវតែនិយាយពាក្យប្រកបដោយប្រយោជន៍ធ្វើឱ្យអ្នកស្តាប់មានការភ្ញាក់រលឹក ស្គាល់អ្វីដែលល្អ ស្គាល់អ្វីដែលអាក្រក់ សំរាប់បំភ្លឺឱ្យមនុស្សលោកសាងសេចក្តីចំរើនរុងរឿងទាំងក្នុងលោកនេះ និង ក្នុងបរលោក ។

**_សម្មាកម្មន្ត** ការងារត្រឹមត្រូវបានដល់អំពើល្អប្រសើរ គឺសាងសីលធម៌ឱ្យកើតមានឡើងដល់សង្គមមនុស្សលោក ជាធម៌ ធ្វើឱ្យមនុស្សលោកមានអរិយធម៌ដ៏ប្រសើរប្រកបដោយសេចក្តីសុខចំរើនបរិបូណ៌ ទាំងអាមិសសុខនិងនិរាមិសសុខ ។

_ **សម្មាកម្មន្ត** ការងារត្រឹមត្រូវមាន ៣ប្រការគឺ :-

**១_បាណាតិបាតា វេរមណី** វៀរសម្លាប់សត្វមានជីវិត ពោលគឺការគោរពឥស្សរភាពនៃជីវិតទូទៅ ព្រោះជីវិតជាទីស្រឡាញ់របស់សត្វទាំងឡាយ មនុស្សសត្វស្រឡាញ់ជីវិត ស្រឡាញ់សេចក្តីសុខ ស្អប់ខ្ពើមទុក្ខលំបាក ។

ការសម្លាប់បំបាត់បង់ជីវិតតែងតែមានការតបតបកវិញ ដែលលោកហៅថា "**ពៀរ**" ពៀរតបពៀរមិនមានទីបំផុតទេ ។

ពុទ្ធភាសិតបានបញ្ជាក់ថា :- ( **ធម្មបទដ្ឋកថា** )

**នហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ៕**

ពៀរមិនដែលរម្ងាប់បានដោយពៀរទេ ពៀរដែលរម្ងាប់ទៅបានដោយសារការមិន ចងពៀរ ធម៌ នេះជាបុរាណកធម៌ ។

ការវៀរចាកសម្លាប់បំបាត់ជីវិតគេឈ្មោះថាបំបាត់មហាភ័យ សាងសេចក្តីសុខឱ្យខ្លួនផងឱ្យអ្នកដទៃផងឬថាធ្វើអភ័យទាន ក្នុងការសាងសេចក្តីសុខ ក្សេមក្សាន្តជូនមនុស្ស និង សព្វសត្វក្នុងលោក ។

សត្វតិរច្ឆានដូចជា គោ ក្របី ជ្រូក បក្សា បក្សីជាដើម ដែលមនុស្សបំផ្លិចបំផ្លាញសម្លាប់វា វាមិនចូលចិត្តនិងមនុស្សទេ វាឃើញមនុស្សវាតែងតែរត់តែងតែបោលឱ្យឆ្ងាយពីមនុស្ស ព្រោះវាខ្លាចមនុស្សផង វាស្អប់ខ្ពើមមនុស្សផង ។

ប៉ុន្តែ ទីណាដែលគេរក្សាថែទាំវាល្អ វាតែងតែស្រឡាញ់មនុស្ស វាមិនទៅណាឆ្ងាយពីមនុស្សទេ ឱ្យផលឱ្យប្រយោជន៍ដល់មនុស្សសមតាមការគួរ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងធម៌ បញ្ញត្តិវិន័យ មិនត្រឹមតែរក្សាសេចក្ដីសុខចំរើនដល់មនុស្សប៉ុណ្ណោះទេ គឺ ទ្រង់ប្រទានអភ័យដល់សព្វសត្វមានជីវិត ទាំងអស់ក្នុង សកលលោកផង ។

ដូច្នេះ កើតជាមនុស្សមានបញ្ញាខ្ពស់ជាងសត្វតិរច្ឆាន ដឹងការខុសត្រូវល្អអាក្រក់ច្រើនជាងសត្វតិរច្ឆាន គួរនាំគ្នារក្សាទាំងសត្វទាំងធម្មជាតិនិងព្រៃព្រឹក្សាឱ្យបានល្អ ដើម្បីបានជារមណីយដ្ឋាននិងជាផាសុកភាពដល់ជីវិតទូទៅព្រមទាំងជាការបំបាត់នូវពៀរវេរាផង ជាការធ្វើឱ្យពិភពមនុស្សលោកនេះមានសេចក្ដីសប្បាយរីករាយក្លាយទៅជាស្ថានសួគ៌ សមតាមសេចក្ដីប្រាថ្នា ។

ការធ្វើកុសលកម្មមានការមិនសម្លាប់សត្វ ការគោរពសុវត្ថិភាពជីវិតមនុស្សរវាងមនុស្ស សង្គមរវាងសង្គម ប្រទេសរវាងប្រទេស ឈ្មោះថាសាងសន្តិភាព ឱ្យមនុស្សនិងសត្វលោក ។

មនុស្សជាតិគួរសាងជីវិតខ្លួនទៅតាមមាគ៌ាដ៏ប្រសើរនៃព្រះអរិយបុគ្គល មិនគួរធ្វើខ្លួនឱ្យជាបន្ទាប្ញឱ្យស្អុកលោកនេះទេ ព្រោះបំណងនៃមនុស្ស-សត្វសុទ្ធតែចង់រស់នៅឱ្យបានយូរចង់បានសេចក្ដីសុខ -សេចក្ដីចំរើនដូចៗគ្នា ។



២_អទិន្នាទានា វេរមណី "វៀរមិនកាន់យកទ្រព្យដែលគេមិនបានឱ្យ" ។ ការគោរពកម្មសិទ្ធិរបស់អ្នកដទៃជាធម៌ ប្រសើរណាស់ ព្រោះថាទ្រព្យសម្បត្តិក៏ដូចជារូបកាយយើងដែរ ជារបស់ដែលបុគ្គលស្ងួនរក្សាទុកដោយប្រពៃ ។

ការមិនគោរពកម្មសិទ្ធិនៃជនដទៃ គឺ ការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃដែលគេខំរកបានមកដោយកម្លាំងកាយ ដោយកម្លាំងប្រាជ្ញាប្រកបដោយធម៌ត្រឹមត្រូវនេះជាហេតុធ្វើឱ្យគេកើតក្ដីក្ដៅក្រហាយ ទុកដូចជាបង្កាត់ភ្លើងនរកឱ្យឆេះសន្ធោសន្ធៅលោកយើងនេះ ។ អំពើនេះជាបាបភ័យធំណាស់ គួរជៀសវាងកុំឱ្យកើតបាន ។ ពិភពលោកដែលវ័យកក់ក្ដៅរន្ធត់ស្លន់ស្លោព្រោះការមិនគោរពសិទ្ធិនេះឯង ។

ទ្រព្យសម្បត្តិក៏ដូចជាអាយុជីវិតយើងគ្រប់គ្នា មនុស្សរស់នៅក្សេមក្សាន្តដោយសារទ្រព្យសម្បត្តិតែទ្រព្យសម្បត្តិកើតឡើងបានដោយសារសម្បទាធម៌ ៤យ៉ាងបានឧដ្ឋានសម្បទាជាដើម ។ អ្នកមិនបានទ្រព្យសម្បត្តិពីមនុស្សទ័លក្រ ។ អ្នកទ័លក្រមិនមានទីឋាននៅក្នុងលោកនេះទេ ព្រោះលោកនេះ របីងរឹងរូសណាស់លុះតែអ្នកមានអំណត់តស៊ូបំពេញនូវសម្បទាទាំងនោះទើបអាចរស់ប្រសើរបាន ។ ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា :- លោកនេះជាទុក្ខ ។

អ្នកលួច ប្លន់ បោកប្រាស់ប្រវញ្ចន៍ ឆក់ ដណ្ដើមទ្រព្យសម្បត្តិជាកម្មសិទ្ធិអ្នកដទៃ ឈ្មោះថាជាអ្នកបំផ្លាញសេចក្ដីសុខគេ និង ជាអ្នកដុតបំផ្លាញនូវខ្លួនផង ។ ដូច្នេះ អ្នកស្រឡាញ់ខ្លួនគួរប្រតិបត្តិតាមមាគ៌ាដ៏ប្រសើរនៃព្រះអរិយបុគ្គល ដើម្បីសេចក្ដីសុខសាន្ត និង សេចក្ដីចំរើនរុងរឿងដល់ខ្លួនផង ដល់ជនទូទៅផង ។

៣-**កាមេសុ មិច្ឆាចារា វេរមណី** "វៀរប្រព្រឹត្តកន្លងនូវប្រពៃណី ពោលគឺការរក្សាក្តីបរិសុទ្ធក្នុងប្រពៃណី ។ ក្នុងសង្គមមនុស្សលោកនេះមានធម៌ប្រកាន់ថា ស្វាមីភរិយាជាគូជីវិត បុត្តធីតាជាទីស្រឡាញ់ពេញចិត្ត។ ការប្រព្រឹត្តកន្លងប្រពៃណីជាហេតុបណ្តាលឱ្យកើតសេចក្តីក្តៅក្រហាយ ។ ដូច្នេះស្វាមីភរិយា ឬ បុត្តធីតាគួរស្ងួនរក្សាប្រពៃណីខ្លួនទុកឱ្យបរិសុទ្ធដោយប្រពៃ ។

មនុស្សជាសត្វដ៏ប្រសើរ ស្គាល់អ្វីដែលគួរនិងស្គាល់អ្វីដែលមិនគួរ គប្បីរក្សាចិត្តទប់ចិត្តរបស់ខ្លួនឱ្យបានល្អ មិនគួរបណ្តែតបណ្តោយចិត្តឱ្យអែរទៅតាមទំនើងខ្លួននោះទេ ។

សតិសម្បជញ្ញៈទុកដូចជាសារថីសេះទុកដូចជាចិត្តទ្រើសទ្រនំ កាយទុកដូចជាតួរថឬរទេះ អ្នកប្រាថ្នាល្អត្រូវយកសតិសម្បជញ្ញៈជាសារថីទប់ខ្សែពីសេចក្តីប៉ងប្រាថ្នាដែលចងសេះពីចិត្តឱ្យនៅនឹង ហើយឱ្យចរទៅតាមផ្លូវត្រង់ឆ្ពោះទៅរកសេចក្តីសុខក្សេមក្សាន្ត ។

ឯការក្រេបផឹកគ្រឿងស្រវឹងនិងការសេពគប់វត្ថុញៀនផ្សេងៗក៏ត្រូវតែវៀរផងដែរ ព្រោះសុរាមេរ័យនិងវត្ថុគ្រឿងញៀននេះនាំឱ្យខូចសុខភាពដល់អាការៈរូបរាងកាយនិងធ្វើឱ្យអន់ខ្សោយទ្រុឌទ្រោមសតិបញ្ញា ។ បើសតិបញ្ញាដែលជាពន្លឺក្នុងខ្លួនអន់ខ្សោយ ហើយអ្វីទាំងអស់ក៏ចុះដុនដាបដែរ។ ភាពជាមនុស្សក៏ក្លាយទៅជាភាពអ្វីមួយទៀតដែលយើងមិនគួរប្រាថ្នា ។

មាគ៌ាទាំងពីរប្រការគឺ **សម្មាវាចា** និង **សម្មាកម្មន្តៈ** បើរួមចូលគ្នាគឺការរក្សាសីល៥ឬសីល៨នេះឯង។ សីលនេះហើយដែលជាដើមនៃកុសលធម៌ទាំង



ពួងជាកាំជណ្តើរទីមួយដែលពុទ្ធបរិស័ទគ្រប់គ្នា ត្រូវប្រតិបត្តិដើរឆ្ពោះទៅរកមគ្គ-ផលនិងនិព្វាន ដែលជាទិសដៅនៃការប្រតិបត្តិធម៌ព្រះពុទ្ធ។ អ្នករក្សាសីលគប្បីតាំងចិត្តថាការរក្សាសីលនេះ គឺដើម្បីដុសលាងចិត្តរបស់ខ្លួនដែលប្រឡាក់ដោយរាគៈទោសៈលោភៈជាដើមឱ្យបានស្អាតបរិសុទ្ធដើម្បីធ្វើ កាយ វាចា ចិត្ត ឱ្យខិតចូលទៅជិតព្រះនិព្វាន។

អ្នករក្សាសីលល្អម៉ត់ចត់បែបនេះចាត់ជាបុគ្គលដ៏ប្រសើរគួរគោរពបូជាហើយសីលរបស់បុគ្គលនោះហៅថា **អរិយកន្តសីល** បានសីលជាទីស្រឡាញ់ស្រឡាញ់សីលស្មើជីវិត ទុកសីលជាជីវិតរបស់ខ្លួន ព្រមទាំងបានឈ្មោះថាជាអ្នកមានការស្មោះត្រង់ចំពោះសីលគឺមិនកុហក់ឬមិនក្បត់ចេតនារបស់ខ្លួនឯង ដែលប្តេជ្ញាថារក្សាសីល កាន់សីលហើយនោះ។ នេះជាផ្លូវនាំទៅកាន់សេចក្តីសុខតាមដំណើរព្រះអរិយបុគ្គល ។

-**សម្មាអាជីវៈ** ការចិញ្ចឹមជីវិតត្រឹមត្រូវ អាជីពត្រឹមត្រូវបានដល់ការវៀរចាក **មិច្ឆាជីវៈ** គឺ ការចិញ្ចឹមជីវិតខុសចាកកន្លងធម៌ ។

ការស្គាល់ប្រមាណក្នុងការចិញ្ចឹមជីវិតជាការកម្រណាស់។ ដើម្បីរស់មនុស្សត្រូវប្រកបការងារស្វែងរកទ្រព្យសម្បត្តិដែលជាមធ្យោបាយឱ្យកើតគ្រឿងប្រើប្រាស់និងចំណីអាហារសម្រាប់ចិញ្ចឹមជីវិត ជីវិតរស់នៅអាស្រ័យដោយអាហារ។ អ្នកណាមានទ្រព្យសម្បត្តិ អ្នកនោះមានជីវិតខ្ពង់ខ្ពស់ ។ បើមានជីវិតខ្ពង់ខ្ពស់ទើបបានឋានៈសមជាមនុស្សក្នុងលោកនេះ។

តែការកសាងជីវិតត្រូវស្គាល់ប្រមាណគឺ ត្រូវស្វែងរកទ្រព្យសម្បត្តិទៅ

តាមកន្លងធម៌ ។ ធ្វើយ៉ាងណាឱ្យកើតទ្រព្យសម្បត្តិផង ឱ្យមានសេចក្ដីសុខដល់ខ្លួនផង ដល់អ្នកដទៃផង ។

អ្នកស្រឡាញ់ខ្លួនគួរវៀរចាកការចិញ្ចឹមជីវិតប្រកបដោយទោស( ទោសកើតដល់ខ្លួន និង កើតដល់បុគ្គលដទៃ) ។

ក្នុងគម្ពីរអង្គុត្តរនិកាយបញ្ចកនិបាត ឧបាសកវគ្គ ព្រះពុទ្ធទ្រង់មានព្រះតម្រាស់ថា ឧបាសក ឧបាសិកា ត្រូវវៀរជំនួញ ៥ ប្រការ គឺ :-

១_**សត្ថវណិជ្ជា** ≈ ជំនួញសស្ត្រាវុធ

២_**សត្តវណិជ្ជា**≈ ជំនួញមនុស្ស

៣_**មំសវណិជ្ជា** ≈ ជំនួញកាប់សត្វលក់

៤_**មជ្ជវណិជ្ជា** ≈ ជំនួញគ្រឿងស្រវឹង

៥_**វិសវណិជ្ជា** ≈ ជំនួញថ្នាំពុល

**_ការវៀរចាកជំនួញលក់អាវុធ** ក្នុងលោកនេះមានការលក់ដូរអាវុធយុទ្ធភ័ណ្ឌ តើអាវុធនេះគេសំរាប់យកទៅធ្វើអ្វី? - គឺមិនមែនសំរាប់យកទៅជាមធ្យោបាយបង្កបង្កើនផលឬសំរាប់ផ្ដល់សុខមាលភាពសុភមង្គលឱ្យមនុស្សលោកនេះទេ ។ ការពិតគឺជាគ្រឿងប្រហារសំរាប់សម្លាប់មនុស្សបំផ្លាញសុខសន្តិភាពក្នុងលោក ។

យើងជាតិជាមនុស្សមិនគួរបើអីទៅសាងគ្រឿងសស្ត្រាវុធ សម្លាប់មនុស្សគ្នាឯងសោះ ។ រីឯអ្នកសាងអាវុធមិនសុទ្ធតែជាមនុស្សល្ងង់នោះទេ គឺមានអ្នកប្រាជ្ញអ្នកចេះអ្នកដឹងជាច្រើនបង្កើតគ្រឿងប្រហារទាំងនេះ ។ ប៉ុន្តែអ្នកមានវិជ្ជាទាំងនោះ



ប្រាសចាកសីលធម៌ បណ្ដោយឱ្យ លោភៈ ទោសៈ មោហៈ និង មហិច្ឆតារបស់ខ្លួនធ្លាក់ទៅក្នុងខ្ញុំកញ្ជះតណ្ហា ចង់ឱ្យខ្លួន ពួកខ្លួនបានមហានុភាពរស់នៅរុងរឿងប្រសើរជាងគេ ញុះញង់អ្នកដទៃឱ្យឈ្លោះគ្នា ឱ្យទិញអាវុធរបស់ខ្លួនទៅធ្វើសង្គ្រាមកាប់ចាក់ប្រល័យជីវិតគ្នា យកអាវុធសំឡុតកំហែងគ្នាឱ្យគេខ្លាចឱ្យគេភ័យតកមាដើម្បីផលប្រយោជន៍ខ្លួនបក្សពួករបស់ខ្លួន ។

អំពើនេះគួរឱ្យស្ដាយណាស់ប្រសិនបើយកចំណេះវិជ្ជា ទ្រព្យសម្បត្តិរបស់ពួកមិត្តសំឡាញ់ទៅប្រើប្រាស់តាមផ្លូវវិរិយបត្តុវិញនោះ សុខសន្តិភាព វឌ្ឍនធម៌ ពិតជានឹងកើតឡើងក្នុងលោកនេះសមតាមសេចក្ដីប្រាថ្នាមិនខាន ។

ព្រះពុទ្ធទ្រង់បញ្ញត្តិមិនឱ្យសាងគ្រឿងសស្ត្រាវុធនិងលក់ដូរអាវុធនេះ ព្រោះអំពើនេះនាំឱ្យកើតបាបាយនភាពដល់សត្វលោកនិងសកលលោក ។ គួរសាធុជនទាំងឡាយវៀរបង់នូវមិច្ឆាជីវៈ នេះ ។

**-ការវៀរចាកជំនួញលក់មនុស្ស** .ក្នុងប្រវត្តិមនុស្សលោកតាំងពីក្នុងអតីតកាលរហូតមកដល់បច្ចុប្បន្នកាលមានអំពើនេះ ។ អំពើចាប់មនុស្សលក់ឬលក់មនុស្សនេះគួរឱ្យរន្ធត់ស្លុប់ស្លែងណាស់ ព្រោះវាជាអំពើបំផ្លាញសិទ្ធិសេរីភាពរបស់មនុស្សយ៉ាងធ្ងន់ធ្ងរនិងថោកទាបបំផុត ។ ធ្វើឱ្យមនុស្សភាពធ្លាក់ទៅជាសត្វតិរច្ឆាន ។ បង្កើតការមើលងាយមើលថោកមនុស្សជាតិគ្នាឯងហួសពីសត្វតិរច្ឆានទៅទៀត ហើយជាអំពើសាហាវព្រៃផ្សៃយ៉ាងកាចសាហាវក្នុងសង្គមមនុស្ស ដែលគួរឱ្យស្អប់ខ្ពើមយ៉ាងក្រៃលែង ។

មនុស្សជាតិគួរបញ្ឈប់អំពើនេះជាបន្ទាន់ដើម្បីសុភមង្គល-មេត្រីរាប់អានគ្នាដោយស្មោះត្រង់ ក្នុងភាតរភាព និង សមភាព ជាមនុស្សដូចគ្នា ។

ការលក់ដូរមនុស្សទុកស្មើនិងការសម្លាប់បំបាត់ជីវិតមនុស្សអ៊ីចឹងដែរ ព្រោះមនុស្សដែលត្រូវគេលក់នោះបាត់បង់សិទ្ធិសេរីភាព និង តម្លៃជាតិជាមនុស្សអស់មិនមានសល់ ។

**- ការវៀរសម្លាប់សត្វយកសាច់លក់ ៖**

អំពើនេះមនុស្សបានចាត់ទុកជាផ្លូវសាងសេដ្ឋកិច្ចមួយដ៏សំខាន់ តែព្រះសម្ពុទ្ធមិនសរសើរអំពើនេះទេ ។ ពុទ្ធបំណងរបស់ព្រះអង្គគឺរំដោះសត្វលោកឱ្យរួចផុតពីភ្លើងទុក្ខភ្លើងកិលេសឱ្យរួចផុតពីការជិះជាន់បៀតបៀនរាយាដព្យាបាទគ្រប់យ៉ាង ។ រីឯព្រះធម៌ទេសនារបស់ព្រះអង្គមិនមែនប្រដៅឱ្យធ្វើល្អ ត្រឹមតែជាតិជាមនុស្សគ្នាឯង ឬ ទេព្ដា មារ ព្រហ្ម ប៉ុណ្ណោះទេ សូម្បីសត្វតិរច្ឆានក៏ព្រះអង្គមានព្រះបំណងឱ្យមានសិទ្ធិសេរីភាពក្នុងការរស់នៅដូចមនុស្សជាតិដែរ ។ ព្រោះមនុស្សនិងសត្វ មានសេចក្ដីស្រឡាញ់ជីវិតដូចគ្នា ចង់រស់នៅឱ្យបានសុខក្សេមក្សាន្តក្នុងលោកនេះ ។ ការបំបាត់ជីវិតគេ ដើម្បីខ្លួនរស់មិនមែនជាមនុស្សធម៌-ទេ ស៊ីសាច់គេឆ្ងាញ់មានសេចក្ដីសប្បាយរីករាយ តែសត្វដែលរងគ្រោះត្រូវគេសម្លាប់ស៊ីនោះបាត់បង់ជីវិតតាមផ្លូវអរិយមគ្គអំពើដូចនេះមិនឈ្មោះថា អំពើត្រឹមត្រូវឡើយ ព្រោះការថ្លឹងនេះមានទម្ងន់មិនស្មើគ្នា ខុសគ្នាឆ្ងាយណាស់ ។

ក្នុងធម្មបទដ្ឋកថា មានពុទ្ធសុភាសិតបញ្ជាក់ថា :-

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**

**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សព្វសត្វទាំងអស់តែងតក់ស្លុតចំពោះអាជ្ញា ព្រោះសត្វទាំងអស់មានជីវិតជាទីស្រឡាញ់ បុគ្គលគួរយកខ្លួនជាឧបមាហើយមិនគប្បីប្រើគេឱ្យសម្លាប់ទាំង



មិនគប្បីសម្លាប់ដោយខ្លួនឯង ។

**សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**

**អត្តនោ សុខមេសានោ បេច្ចសោ ន លភតេ សុខំ ។**

សត្វទាំងឡាយសុទ្ធតែចង់បានសេចក្ដីសុខ តែបើអ្នកណាចង់បានសេចក្ដីសុខដើម្បីខ្លួនហើយសំឡុតកម្ហោច បៀតបៀនគេដោយអាជ្ញា (រំពាត់) អ្នកនោះទោះបី នៅក្នុងលោកនេះក្ដី ទៅក្នុងលោកខាងមុខក្ដី រមែងមិនបានទទួលសេចក្ដីសុខឡើយ ។

ពុទ្ធសុភាសិតទាំងពីរបទខាងលើនេះ បញ្ជាក់ឱ្យយល់ថាព្រះពុទ្ធសាសនាជាសាសនាប្រាកដនិយម មិនមែនលំអៀងទៅតាមបំណងតែម្ដងទេ ឱ្យសត្វពួកនេះរស់ សត្វពួកនោះស្លាប់នោះទេ គឺសាសនាកប្ដូរាទប្រកបដោយហេតុនិងផល អ្នកណាធ្វើល្អទទួលផលល្អ អ្នកណាធ្វើអាក្រក់ទទួលផលអាក្រក់ មិនមែនឃើញសថាជាខ្មៅឬឃើញខ្មៅថាជា ស នោះទេ ហើយមិនមានអ្នកណាទទួលផលល្អ ឬ ផលអាក្រក់ ជំនួសខ្លួនអ្នកធ្វើនោះបានឡើយ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា :- **អក្ខាតារោ តថាគតា បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា** តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវប៉ុណ្ណោះ អ្នកណាបានប្រតិបត្តិដើរតាម អ្នកនោះនឹងបានរួចចាកអន្ទាក់ចំណងរបស់មារ ។

រីការគោរពឥស្សរភាពនៃជីវិតមនុស្សនិងសត្វចាត់ជាមាគ៌ាដ៏ប្រសើរ សំរាប់សាងសុខសន្តិភាពនិងក្ដីមនោរម្យរីករាយក្នុងលោកនេះ ។

**ការវៀរជំនួញគ្រឿងស្រវឹង និង គ្រឿងញៀន :-**

មនុស្សជាសត្វដ៏ប្រសើរ ព្រោះមានបញ្ញាខ្ពស់ជាងពួកសត្វនានា មានសីលធម៌ ស្គាល់ល្អ ស្គាល់អាក្រក់ មានការសិក្សាយល់ហេតុនិង ផល មានចិត្តមេត្តាករុណា ។ គុណធម៌ទាំងនេះហើយដែលធ្វើឱ្យលោកនេះមានសេចក្ដីសុខ ចំរើន ។

បើគេយកគ្រឿងស្រវឹង គ្រឿងញៀន ទៅផ្ដល់ ឬ លក់ឱ្យមនុស្ស ឈ្មោះថាធ្វើឱ្យមនុស្សអប្បអន់បញ្ញា បាត់បង់ចិត្តមេត្តា ករុណា វង្វេង វង្វេងវង្វាង សតិសម្បជញ្ញៈខ្សោយសុខភាពទាំងកម្លាំងកាយ កម្លាំងចិត្ត ឈ្មោះថាធ្វើឱ្យគុណធម៌របស់មនុស្សធ្លាក់ចុះ ។ (ដូចបានលើកឡើងនៅខាងដើម ) ។

បើមនុស្សយល់លាបកថាជាថ្កាបើយេ សេចក្ដីសុខក្នុងលោក នឹង មិនអាចកើតមានជាស្ថាពរបាន ទុក្ខទោសព្រោះថ្នាក់របស់សត្វលោក ភាគច្រើនកើតមកពីមនុស្សយកខុសជាត្រូវ យកត្រូវជាខុសនេះឯង ។ ការនេះគួរឱ្យភ័យខ្លាច ជាទីបំផុត ។

អ្នកប្រាថ្នាសេចក្ដីសុខសេចក្ដីចំរើនដល់ខ្លួននិងអ្នកដទៃ គួរគប្បីវៀរបង់គ្រឿងញៀន ហើយមិនគួរយកវត្ថុទាំងនេះធ្វើជាអាជីពរបស់ខ្លួនឡើយ ដើម្បីរួមគ្នាសាងពិភពលោកនេះ ឱ្យក្លាយទៅជាស្ថានសួគ៌ សមតាមសេចក្ដីប្រាថ្នា ។

**ការវៀរចាកជំនួញគ្រឿងពិសពុល:** ការយកវត្ថុ ពិសពុលគ្រប់បែបធ្វើជាអាជីវកម្មប្រចាំជីវិតមិនគួរទេ ព្រោះថាវត្ថុពិសពុលគ្រប់បែបយ៉ាង នាំឱ្យកើតហាយនភាពដល់មនុស្សសត្វក្នុងលោក ។ ថ្នាំពុលផ្សេងៗ ដែលគេផ្សំពីរុក្ខជាតិពីវត្ថុគីមីដែលចេញទៅជាជាតិម្សៅ ប្រេង ផ្សែង ក្លិន ជាដើម សុទ្ធតែធ្វើឱ្យមនុស្សនិងសត្វស្លាប់បាន ។ វត្ថុទាំងនេះដូចជាគ្រឿងសស្ត្រាវុធដ៏មានអានុភាពខ្លាំង



ក្លាហោសក្នុងការបំផ្លាញជីវិតមនុស្សសត្វ ។ ដូច្នេះគួរសាធុជនវៀរបង់នូវជំនួញគ្រឿងពិសពុលនេះ ។

អ្នកប្រកបការងារជាសម្មាអាជីព គឺជាមនុស្សមានកាយវាចាបរិសុទ្ធ ធ្វើឱ្យខ្លួនឯងនិងអ្នកដទៃមានសេចក្ដីសុខក្សេមក្សាន្ត ហើយអ្នកនោះបាននាមថា ជាអរិយជន ជាបុគ្គលប្រសើរក្នុងលោក ។

គួរសាធុជនទាំងឡាយវៀរបង់មិច្ឆាអាជីវៈឱ្យជ្រះស្រឡះ ហើយបំពេញសម្មាអាជីវៈ ឱ្យបានបរិបូណ៌ ជានិច្ចនិរន្តរ៍ ។

អង្គទាំងបីនៃ អដ្ឋង្គិកមគ្គគឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ដែលបានអធិប្បាយខ្លីៗមកនេះ ចាត់ចូលទៅក្នុងពួកសីល (សីលខន្ធ) សីលនេះជាគ្រឹះនៃកុសលធម៌ទាំងពួងអ្នកប្រាថ្នាសេចក្ដីសុខត្រូវប្រតិបត្តិធម៌នេះឱ្យបាន ដើម្បីលុះធម៌ជាន់ខ្ពស់តទៅទៀត បើមិនបានគុណធម៌នេះទុកជាគ្រឹះទេ គេមិនអាចឡើងទៅកាន់ថ្នាក់ធម៌ជាន់ខ្ពស់ជាលំដាប់បានឡើយ ព្រមទាំងមិនអាចសាងសុភមង្គលសុខដុមរមនាឱ្យកើតឡើងដល់ខ្លួនឯងដល់គ្រួសារ និង សង្គមមនុស្សលោកនេះឱ្យសប្រេចតាមបំណងបានឡើយ ។

- **សមាធិខន្ធ** "ពួកសមាធិ" ពួកធម៌នេះសំរាប់ទូន្មានចិត្ត ហាត់ពត់ចិត្តរក្សាចិត្តឱ្យនៅរងថ្លាដូចដើមដែលលោកហៅថា ភវង្គចិត្ត ឬ បកតិចិត្ត ។ តាមប្រក្រតីចិត្តជាធម្មជាតិថ្លាស្អាតបរិសុទ្ធតែដោយមានអាគន្តុកឧបកិលេស ចូលទៅធ្វើឱ្យសៅហ្មង ដូចជាបរិយាកាសសង្គម ប្រពៃណី ទំនៀមទំលាប់ជាដើម ឬតាមរយៈទ្វារទាំង ៥ មានចក្ខុទ្វារ ជាដើម ធ្វើឱ្យចិត្តថ្លាស្អាតក្លាយទៅជាចិត្តល្អក់សៅហ្មង ។

ព្រះពុទ្ធជាម្ចាស់ទ្រង់បានបញ្ជាក់ថា :- **បភស្សរមិទំ ចិត្តំ ភិក្ខវេ អាគន្តុកេហិ ឧបកិលេសេហិ ឧបកិលិដ្ឋំ** "ម្នាលភិក្ខុ"ទាំងឡាយចិត្តនេះមានពន្លឺភ្លឺផ្លេកៗល្អណាស់ តែដែលក្លាយទៅជាចិត្តសៅហ្មង ព្រោះមានឧបកិលេសចូលទៅធ្វើឱ្យកករល្អក់ "ធម្មបទ" ។

បើចិត្តសៅហ្មងហើយ ចិត្តនេះរបិញរបុញមានពុតត្បុតច្រើនណាស់ ខិលរប៉ិលរប៉ូចដូចសត្វស្វា វាតែងតែទើងទៅតាមទំនើងរបស់វា ទូន្មានបានដោយលំបាក រក្សាបានដោយកម្រ ។ តែទោះបីដូចម្តេចក្តី អ្នកមានប្រាជ្ញាអាចទូន្មានចិត្តធ្វើឱ្យចិត្តថ្លាបរិសុទ្ធដូចដើម គួរដល់ការងារបានដូចព្រះតម្រាស់ថា :-

**ផន្ទនំ ចបលំ ចិត្តំ ទុររក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។**

ចិត្តជាធម្មជាតិរវើរវាយ ស្ទុះស្ទា អន្ទះសា រក្សាបានដោយកម្រ ប្រដៅបានដោយលំបាក តែលោកអ្នកប្រាជ្ញអាចធ្វើចិត្តឱ្យត្រង់បានដូចគេពត់សរ ឱ្យត្រង់ដូច្នេះឯង "ធម្មបទកថា" ។

ចិត្តដែលគេទូន្មាន ឱ្យបានបែបបទតាមមាគ៌ាព្រះពុទ្ធសាសនាហើយ ជាចិត្តត្រង់ណាស់ តម្រង់ទៅត្រង់ណា ត្រង់ទៅត្រង់នោះ បានសេចក្តីថាបង្គាប់ចិត្តបានគឺ យើងជាម្ចាស់ចិត្ត មិនមែនដូចកាលដើមចិត្តជាម្ចាស់យើងនោះទេ "**តណ្ហាទាសោ**" យើងជាខ្ញុំកញ្ជះតណ្ហានោះទេ ។ ចិត្តដែលគេអប់រំឱ្យទន់ភ្លន់គួរដល់ការងារហើយនោះ ជាចិត្តមានប្រសិទ្ធភាពណាស់ ខ្លាំងក្លាណាស់ មិនមានអ្វីក្នុងលោកខ្លាំងក្លាស្មើនិងចិត្តដែលអប់រំមានបែបបទនេះទេ ។ ព្រះអរិយបុគ្គលដែលបាន សម្រេចដល់ព្រះនិព្វាន ក៏ ព្រោះតែលោកបានព្យាយាមអប់រំចិត្ត ឱ្យកើត



បញ្ញាញាណចាក់ធ្លុះអរិយសច្ចធម៌នេះឯង ។

ឯធម៌ទូន្មានចិត្តហ្នឹងបានដល់ធម៌ ៣ប្រការ គឺ :- សម្មាវាយាម សម្មាសតិ សម្មាសមាធិ ដែលជាអង្គនៃអដ្ឋង្គិកមគ្គ នោះឯង ។ លោករួបហៅថា សមាធិខន្ធ "ពួកសមាធិ" ។

-**សម្មាវាយាម** "ព្យាយាមត្រឹមត្រូវ" គឺសំដៅយកសេចក្តីប្រឹងប្រែងស្រវាស្រទេញ ធ្វើអំពើល្អ ធ្វើហើយធ្វើទៀត មិនរាថយ លុះត្រាតែសម្រេចផលប្រយោជន៍សមតាមសេចក្តីប្រាថ្នា ។ **វាយាម** សេចក្តីព្យាយាមនេះ គឺ លោកសំដៅយកសេចក្តីព្យាយាមធ្វើអំពើល្អ ដែលនាំឱ្យកើតសេចក្តីសុខចំរើនមិនមែនសំដៅយកសេចក្តីព្យាយាម ធ្វើអំពើអាក្រក់នោះទេ ។

ឯ **សម្មាវាយាម** សេចក្តីព្យាយាមត្រឹមត្រូវនេះមាន ៤ ប្រការគឺ :-

១- **សំវរប្បធាន** សេចក្តីព្យាយាមប្រុងប្រយ័ត្ន កុំឱ្យអកុសលធម៌ដែលមិនទាន់កើតឡើងឱ្យកើតឡើងបាន ។

២- **បហានប្បធាន** សេចក្តីព្យាយាមលះបង់នូវអកុសលធម៌ ដែលកើតឡើងហើយ ។

៣- **ភាវនាប្បធាន** សេចក្តីព្យាយាមចំរើនកុសលធម៌ ដែលមិនទាន់កើតឡើង ឱ្យកើតឡើងក្នុងរាល់សកម្មភាពរបស់ខ្លួន ។

៤- **អនុរក្ខនាប្បធាន** សេចក្តីព្យាយាមរក្សាការពារនូវកុសលធម៌ទាំងឡាយដែលធ្វើបានហើយនោះ កុំឱ្យវិនាសបាត់បង់ទៅវិញ គឺ ខំធ្វើ ខំរក្សាថែទាំឱ្យតាំងនៅនិងរីកចំរើនជាភិយ្យោភាពតទៅទៀត ។

គុណធមិទាំង ៤ប្រការនេះ ជាកម្លាំងជួយបំបែរផ្ចិតចិត្តអាក្រក់ឱ្យក្លាយទៅជាល្អ ជួយឧបត្ថម្ភចិត្តល្អ ដែលទូន្មានបានហើយឱ្យតាំងនៅ ហើយឱ្យរីក ទូលំទូលាយតទៅទៀត គឺ ផ្លាស់ចិត្តអាក្រក់ឱ្យទៅជាចិត្តល្អ និងជួយចិត្តល្អឱ្យរីតតែល្អក្រៃលែង ។

មនុស្សដែលមិនទាន់ទូន្មានខ្លួនតាមបាតិាដ៏ប្រសើរនេះ ធ្វើអ្វីធ្វើបានតែអំពើអាក្រក់ ព្រោះផ្ចិតចិត្តវាធ្លាប់តែញៀនញាបក្នុងអំពើអាក្រក់ ធ្វើល្អបានដោយកម្របោាស់ ។ ឯមនុស្សដែលបានខ្លួនទូន្មានហើយ ធ្វើអ្វី ធ្វើបានតែអំពើល្អ ព្រោះផ្ចិតចិត្តវាបាក់ទៅខាងល្អ ធ្វើអាក្រក់បានដោយកម្រពេកណាស់ ។

សេចក្តីទុក្ខ សេចក្តីក្តៅក្រហាយ តែងកើតមានដល់បុគ្គលដែល មិនបានទូន្មានខ្លួន ។ មនុស្សខ្លះយល់ថាចិត្តនេះជាធមិដែលគេទូន្មានមិនបានអ្នកយល់យ៉ាងនេះ គឺគេចង់បណ្តោយឱ្យចិត្តប្រព្រឹត្តទៅតាមទំនើងរបស់វា ។

ប្រវត្តិរបស់មនុស្សលោក បានបង្ហាញឱ្យឃើញថា មានមនុស្សច្រើននាក់ដែលគេបានសាងខ្លួនឱ្យប្រសើរគឺ ពីភាពក្រីក្រឱ្យទៅជាមហាសេដ្ឋី ពីភាពល្ងង់ខ្លៅឱ្យទៅជាអ្នកប្រាជ្ញ ពីបុថុជ្ជន ឱ្យទៅជាអរិយជន មានព្រះអរហន្តខីណាស្រពជាដើម ឆ្លងពីទីទុក្ខលំបាកទៅកាន់បរមសុខ ។ លទ្ធផលសម្រេចទាំងនេះ គឺកើតមកពីការអប់រំទូន្មានចិត្តឱ្យមានបែបបទនេះឯង ។

ព្រះពុទ្ធវចនៈទាំងមូលដែលលោកចែកជា វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ឬ និយាយថាមាន = ៨៤000ធម្មខន្ធនោះ បើពោលដោយខ្លីមានតែ ៣ មាត់គឺ កុំធ្វើអំពើអាក្រក់ ធ្វើតែអំពើល្អ ធ្វើឱ្យចិត្តថ្លាស្អាតបរិសុទ្ធ ដូចពុទ្ធឱវាទត្រាស់ថា :-



**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ ៕**

ធម្មទាំងអស់នេះ បើរួមមកមានត្រឹមតែមួយមាត់គឺ ការទូន្មានចិត្ត ។ ចិត្តដែលបុគ្គលទូន្មានល្អហើយតែងតែនាំសុខមកឱ្យ ពុទ្ធភាសិតថា :-

**ចិត្តំ ទន្តំ សុខាវហំ ៕** (ធម្មបទដ្ឋកថា)

ដូច្នេះ សេចក្តីសុខជាទីប្រាថ្នារបស់មនុស្សលោក បានមាតិាដើរទៅដល់ ឯមាតិាសម្រាប់ដើរទៅនោះបានដល់ "សម្មាវាយាម "ព្យាយាមត្រឹមត្រូវ " ដូចពុទ្ធប្រាស់ថា:- **វីរិយេន ទុក្ខមច្ចេតិ** គេរួចផុតពីទុក្ខបានដោយវិរិយភាព ។

**សម្មាសតិ** "សេចក្តីរលឹកត្រឹមត្រូវ" ធមិនេះទាក់ទងដល់សម្បជញ្ញៈ គឺសតិការលឹក សម្បជញ្ញៈការដឹងខ្លួន។ ធមិពីរប្រការនេះមានប្រយោជន៍ណាស់សំរាប់មនុស្ស។ មនុស្សត្រូវបណ្តុះធមិទាំងពីរនេះឱ្យកើតមានក្នុងខ្លួន។ អ្នកណាមិនមានធមិទាំងពីរនេះនៅក្នុងខ្លួន អ្នកនោះទុកដូចជាមនុស្សស្លាប់បានន័យថា "មិនដឹងអ្វីទាំងអស់ គ្មានការភ្ញាក់រលឹកដឹងខ្លួន " ។ ធមិពីរនេះហៅថាជាពហុបការធមិ " ធមិមានឧបការគុណច្រើន ។

សតិនិងសម្បជញ្ញៈ ទុកដូចជាឆ្មាំនៅយាមរក្សាច្រកឬទ្វារទាំង ៥ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មិនឱ្យបាបអកុសលធមិ ចូលមកអុកឡុកចិត្តបាន ។ លោកបញ្ជាក់ថា ច្រក ឬ ទ្វារទាំង ៥ នេះ ជាច្រកចេញចូលទាំងបុណ្យទាំងបាប ។ សតិនិងសម្បជញ្ញៈ ត្រូវត្រួតពិនិត្យមើល បើអារម្មណ៍ខាងក្រៅដែលចូលមកនោះ មានភាពជាកុសលធមិដូចជា អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អវិហឹសា ជាដើមធ្វើដំណើរចូលមកត្រូវអនុញ្ញាតឱ្យចូល តែបើពិនិត្យ

ទៅឃើញថាមានភាពមិនល្អទេមាន លោភៈ ទោសៈ មោហៈ អភិជ្ឈា ព្យាបាទ និវរណៈឧបកិលេសជាដើម ចូលមកក្រឡុកធ្វើឱ្យសៅហ្មង ឱ្យកករល្អក់ដួងចិត្ត បង្កការវិនាសអន្តរាយហើយត្រូវឃាត់ទុកកុំឱ្យចូលមកបាន ។

លោកប្រៀបធៀបថា រូបរាងកាយនេះទុកជានគរមួយយ៉ាងធំ ចិត្តទុកដូចជាព្រះអធិរាជ ឬ ប្រធានាធិបតីដែលសោយរាជ្យ ឬ គ្រប់គ្រងនូវនគរកាយនេះ ឯទ្វារទាំង ៥ មានចក្ខុទ្វារជាដើម ទុកដូចជាផ្លូវគមនាគមន៍ និង ស្ថានីយ៍ ប្រែសណើយ៍ សំរាប់ទាក់ទងទៅគ្រប់ទិសទី សតិ និង សម្បជញ្ញៈ ទុកដូចជានគរបាល កងតម្រួត ឬ ក្រុមគយ សម្រាប់យាមគយគន់ត្រួតពិនិត្យមើលអ្នកណាដែលចូលមកក្នុងនគរនេះតាមផ្លូវ តាមច្រកនានា ឬ តាមព្រំដែននគរ បើឃើញមនុស្សល្អ ជនសុចរិតមានច្បាប់ មានការអនុញ្ញាតត្រឹមត្រូវគប្បីបើកផ្លូវឱ្យចូលទៅគាល់ព្រះអធិរាជ ឬ ឱ្យចូលទៅជួបនិង ប្រធានាធិបតី តែបើគន់គយ ពិនិត្យឆែកឆេរទៅឃើញថា គ្មានច្បាប់ត្រឹមត្រូវទាំងជង្វាយសួយសារអាករ ដែលនាំទៅថ្វាយស្តេចឬជូនប្រធានាធិបតីនោះ ជាវត្ថុមិនស្របច្បាប់ ជាវត្ថុមានគ្រោះថ្នាក់ មនុស្សនេះជាមនុស្សបន្លំមានពុតត្បុតអាក្រក់ ត្រូវហាមឃាត់កុំឱ្យចូលមកក្នុងប្រទេស ទាំងមិនឱ្យទៅជួបព្រះមហាក្សត្រ ឬ ប្រធានាធិបតី ឡើយ ។

យ៉ាងណាមិញ ការគោរពប្រតិបត្តិធម៌គឺការគ្រប់គ្រងនគរកាយនិងចិត្តរបស់ខ្លួនម្នាក់ៗ ឱ្យបានល្អស្អាតបរិសុទ្ធផុតគ្រោះថ្នាក់ ពីកិលេសសៅហ្មង ក៏មានឧបមាយ៉ាងនោះដែរ ។

ការគ្រប់គ្រងចិត្តនិងការសង្រួមក្នុងសំវរធម៌មានប្រយោជន៍ណាស់ ព្រោះរារាំងខ្ទប់រារាំងក្កកិលេស មិនឱ្យទៅធ្វើឱ្យប្រឡាក់ចិត្តឥរវែងហើយវែងទៀត ។

ដូច្នេះត្រូវបណ្តុះសតិសម្បជញ្ញៈ ហើយប្រស់ឱ្យរស់រវើកជានិច្ចកុំឱ្យធម៌នេះងាប់ ។ គុណធម៌ គឺ សតិ និង សម្បជញ្ញៈនេះមិនមែនសម្រាប់យាមឃ្លាំមើលតែអនិដ្ឋារម្មណ៍ ខាងក្រៅដែលចូលមកតាមទ្វារទាំង ៥ ប៉ុណ្ណោះនោះទេ ពិសេសគឺឃ្លាំមើលអំពើរបស់កាយ របស់វេទនា របស់ចិត្តនិង របស់មនោគតិ គឺ អារម្មណ៍ជាតួធម៌នេះទៀតផង ។ ដើម្បីឱ្យដឹងថា " អ្វីទាំងអស់សុទ្ធតែស្ថិតនៅក្នុងព្រះត្រៃលក្ខណ៍ ។

ចំពោះអំពើរបស់កាយ គួរប្រស់ឬ ដាស់សតិសម្បជញ្ញៈដោយអានាបានស្សតិកម្មដ្ឋាន ជាកម្មដ្ឋានទាក់ទងដោយកាយ ដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ ។

ចំពោះវេទនា គួរដាស់សតិសម្បជញ្ញៈ ឱ្យរស់ឡើងជានិច្ចដើម្បីដឹងឱ្យទាន់វេទនា ឬ ផស្សៈដែលជាទុក្ខវេទនាក្តី ជាសុខវេទនាក្តី ឬ ជាអសុខមទុក្ខវេទនាក្តី គឺតាមឱ្យដឹងទាន់ថា វេទនាកើតឡើងហើយរលត់ទៅវិញក្នុងវេទនានោះ ។

ចំពោះអំពើរបស់ចិត្ត គួរប្រើសតិសម្បជញ្ញៈ តាមឱ្យដឹងទាន់ដូចវេទនាដែរគឺឱ្យដឹងថា មានរាគចិត្ត ទោសចិត្ត ឬ បដិឃចិត្ត ឬក៏មោហចិត្ត កើតឡើងឬទេពុំនោះសោត មើលនីវរណធម៌ ឱ្យដឹងថា សភាវធម៌នេះកើតឡើងដូចម្តេច ហើយរលត់ទៅវិញដូចម្តេច ។

ចំពោះមនោគតិ គំនិត សញ្ញា និង អារម្មណ៍ ក៏ត្រូវតែប្រើសតិសម្បជញ្ញៈ តាមដឹងឱ្យទាន់ដូចគ្នា គឺឱ្យដឹងថាកើតឡើងដូចម្តេច និង រលត់ទៅវិញដូចម្តេច ។

ការប្រស់ ឬ ដាស់សតិសម្បជញ្ញៈ ឱ្យរស់រវើកចំពោះធម៌ ៤ ប្រការនេះមានសំដែងជាអនេកបរិយាយនៅក្នុងមហាសតិបដ្ឋានសូត្រ ។

~ **សម្មាសមាធិ** "សមាធិត្រឹមត្រូវ" ការតំកល់ចិត្តឱ្យនឹងនៅដោយប្រពៃមិនឱ្យរវើរវាយ មិនឱ្យអណ្តែតអណ្តូង រាយមាយគ្មានព្រំដែនហៅថា សមាធិ។ ចិត្តដែលតាំងនៅមាំក្នុងសមាធិប្រសើរណាស់ ប្រើជាប្រយោជន៍បានផលគ្រប់ប្រការ គឺជាកញ្ចក់ដ៏ភ្លឺថ្លា ឆ្លុះមើលសភាវធម៌ទាំងឡាយឃើញពិតទៅតាមពិត ។

សមាធិមានច្រើនប្រការណាស់ ។ ក្នុងគម្ពីរវិសុទ្ធិមគ្គសំដែងពីកម្មដ្ឋានមាន ៤០ប្រការទុកជាច្បាប់សំរាប់ប្រតិបត្តិ ធ្វើសមាធិកម្មដ្ឋានបាត់ពត់ទូន្មានចិត្តមានមូលកម្មដ្ឋានជាដើម រហូតដល់ឈានសមាបត្តិ ។

ចិត្តដែលយោគាវចរបុគ្គលបានទូន្មានល្អហើយ ជាចិត្តមានប្រសិទ្ធិភាពប្រសើរណាស់ ។ ព្រោះអាចឱ្យសម្រេចប្រយោជន៍ មិនត្រឹមតែក្នុងលោកនេះទេ រហូតដល់មគ្គផលព្រះនិព្វានទៀត ។

ក្នុងធម្មបទកថា មានពុទ្ធភាសិតបញ្ជាក់ថា :-

**ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា**
**សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ២**

ចិត្តដែលបុគ្គលតំកល់ត្រូវហើយ នឹងផ្តល់ផលប្រយោជន៍ឱ្យបុគ្គលនោះប្រសើរជាងមាតា បិតា ឬ ពួកញាតិកាទាំងឡាយផ្តល់ឱ្យទៅទៀត ។

ប៉ុន្តែ បើចិត្តដែលបុគ្គលតំកល់ខុស លុះទៅក្នុងអំណាចតណ្ហា រាគៈ លោភៈ ទោសៈ មោហៈ ជាដើមរមែងជួបប្រទះសេចក្តីទុក្ខលំបាកច្រើនប្រការ ។



ពុទ្ធសុភាសិតបានបញ្ជាក់ថា :-

**ទិសោ ទិសំ យន្តំ កយិរា វេរីវា បន វេរិនំ**
**មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ២**

ចោរឃើញចោរ ឬ បុគ្គលដែលមានពៀរឃើញមនុស្សដែលមានពៀរនិងគ្នា រមែងធ្វើសេចក្តីវិនាសអន្តរាយដល់គ្នា និង គ្នា មិនខានឡើយ ។ ឯចិត្តដែលបុគ្គលតំកល់ខុសហើយ រមែងផ្តល់សេចក្តីទុក្ខទោសដល់បុគ្គលនោះ ច្រើនជាងចោរនិងបុគ្គលមានពៀរធ្វើដល់គ្នានិង គ្នា នោះទៅទៀត ។ "ធម្មបទដ្ឋកថា"

ដោយឃើញគុណនៃការតំកល់ចិត្តត្រូវ និង ឃើញទោសនៃការតំកល់ចិត្តខុសទើបអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើមបានទូន្មានសត្វលោកឱ្យខំព្យាយាមអប់រំចិត្តឱ្យបានល្អ តាមបែបបទនៃអង្គទាំង ៣ ក្នុង អដ្ឋង្គិកមគ្គ គឺ សម្មាវាយាម សម្មាសតិ សម្មាសមាធិ នេះឯង ។

~ **បញ្ញាខន្ធ** "ពួកបញ្ញា" ។ បញ្ញាជាពន្លឺប្រសើរបំផុតមិនមានពន្លឺអ្វីក្រៃលែងជាងបញ្ញានេះទេ ពន្លឺប្រទីប ពន្លឺព្រះច័ន្ទភ្លឺបានតែពេលយប់ ពន្លឺព្រះអាទិត្យ ភ្លឺបានតែពេលថ្ងៃ ។ ឯពន្លឺបញ្ញាភ្លឺបានទាំងយប់ទាំងថ្ងៃ ។

**នត្ថិ បញ្ញា សមា អាភា** "ពន្លឺអ្វីស្មើដោយបញ្ញាមិនមាន ។ "ធម្មបទដ្ឋកថា"

ពន្លឺបញ្ញានេះ មិនមែនគ្រាន់ តែបំភ្លឺមើលវត្ថុអ្វីៗ នៅក្នុងលោកនេះឱ្យឃើញជាក់ច្បាស់ប៉ុណ្ណោះទេ គឺបំភ្លឺមើលឃើញធម៌បានពិតទៀតផង គឺមើលឃើញ **សច្ចធម៌** ដោយពិតឥតសង្ស័យដែលមំសចក្ខុ មិនអាចមើលឃើញបានឡើយ ។

បញ្ញាអាន២ប្រការគឺ លោកិយបញ្ញានិង លោកុត្តរបញ្ញា ។ ការចេះដឹងចំណេះវិជ្ជាឬការចេះដឹងអ្វីៗ នៅនាលោកនេះ ហៅថា លោកិយបញ្ញា ។ ឯការ

ចេះដឹងនូវសភាវធម៌តាមការពិត ឬ ការចេះដឹងឧបាយរំដោះខ្លួន ឱ្យរួចចាកទុក្ខ ហួសពីលោកិយបញ្ញាទៅទៀត ហៅថា លោកុត្តរបញ្ញា ។

នៅក្នុងអដ្ឋង្គិកមគ្គ អង្គដែលរួមចូលក្នុងបញ្ញាខន្ធ "ពួកបញ្ញា" នេះមាន ២គឺ សម្មាសង្កប្បៈ និង សម្មាទិដ្ឋិ ។

~ **សម្មាសង្កប្ប** : "ការត្រិះរិះត្រឹមត្រូវ" បានដល់ឧត្តមគតិរំដោះខ្លួនឱ្យរួចចាកទុក្ខ មាន៣ យ៉ាង :-

**១~នេក្ខម្មសង្កប្បៈ** ការត្រិះរិះរំដោះខ្លួនឱ្យចេញផុតចាកកាមសេចក្តីពិត ចិត្តមនុស្ស តែងធ្លាក់ចុះទៅក្នុងតាម គឺវត្ថុកាម និង កិលេសកាម ។

ការទូន្មានចិត្តមិនឱ្យជាប់ជំពាក់ នៅក្នុងអារម្មណ៍គឺរូប សម្លេង ក្លិន រស សម្ផស្ស ឬ ការសង្រួម ភ្នែក ត្រចៀក ច្រមុះ អណ្តាយ កាយ មិនឱ្យភ្លើតភ្លើនហួសប្រមាណ ដែលជាហេតុនាំឱ្យកើតទុក្ខក្រវល់ ក្រវាយ ក្នុងវដ្តសង្សារនេះ ។ ការត្រិះរិះចេញ ចាកកាមនេះ មិនមែនជាការខូចបង់អ្វីទេ គឺជាការដកចិត្ត ឱ្យចេញផុតពីភ្លើងទុក្ខ ភ្លើងកិលេស ឆ្លងដល់សិវបាន បរមសុខក្សេមក្សាន្ត។ នេះហៅថា នេក្ខម្ម ឬ វិមុត្តិ "ការរួចចាកភ្លើងទុក្ខ និង ភ្លើងកិលេស ។

**២~អព្យាបាទសង្កប្ប** ការត្រិះរិះមិនព្យាបាទ តាមធម្មតាចិត្តមនុស្សជាធម្មជាតិត្រជាក់ ប៉ុន្តែ កាលបើមានបដិឃៈ សេចក្តីថ្នាំថ្នាក់ចិត្តកើតឡើង ព្យាបាទ កោធ គំនុំគុំគួន ក៏កើតមានព្រម ចិត្តក៏ក្លាយទៅជាក្តៅ ចិត្តភ្លើង ដុតរោលទាំងខ្លួនឯងទាំងអ្នកដទៃឱ្យមានសេចក្តីទុក្ខក្តៅក្រហាយ ។

អ្នកមានបញ្ញា មានសតិសម្បជញ្ញៈ មិនបណ្តោយឱ្យព្យាបាទ កោធ : ទោសៈ រេះចិត្តលោកបានទេ លោកតែងយកទឹកត្រជាក់ គឺ មេត្តា ទៅស្រោច



ស្រប់ភ្លើងនោះឱ្យរលត់ជានិច្ច ។

**៣~ អវិហឹសាសង្កប្បៈ** ការត្រិះរិះមិនបៀតបៀន ដូចបានបញ្ជាក់ហើយថា មនុស្សសត្វចង់បានសេចក្តីសុខ "**សុខកាមានិ ភូតានិ**" សេចក្តីសុខជាកំពូលនៃសេចក្តីប្រាថ្នារបស់សត្វលោក ។

អ្នកឃើញតែសេចក្តីសុខផ្ទាល់ខ្លួន មិនឃើញអ្នកដទៃផង នឹង នាំឱ្យកើតសេចក្តីក្តៅក្រហាយទល់ទុក្ខវេទនាមិនត្រឹមតែអ្នកដទៃនោះទេ វាធ្លាក់មកដល់ខ្លួនអ្នកបៀតបៀនគេនោះផង ។

ធម៌ទាំងពីរយ៉ាងគឺ អព្យាបាទ និង អវិហឹសានេះ ជាគុណធម៌ធ្វើឱ្យ លោកនេះបានសេចក្តី សុខត្រជាក់ត្រជុំ ទុកដូចជាទឹកអម្រិត ប្រស់ព្រំលោកនេះ ឱ្យបានសន្តិភាព ។

ការទាញចិត្តឱ្យចេញពីវត្ថុកាម និង កិលេសកាម ពីព្យាបាទ ពីការបៀតបៀន វាជាការលំបាក មិនមែនជារឿងងាយនោះទេ ប៉ុន្តែ បើយើងមានព្យាយាមខំអប់រំខ្លួនទៅតាមលំអានអរិយមគ្គនេះ នឹងអាច សម្រេចផលដ៏ប្រសើរសមតាមបំណងប្រាថ្នាពុំខានឡើយ ដូចព្រះអរហន្តាខីណាស្រព ជាគំរូនោះស្រាប់ ។

~ **សម្មាទិដ្ឋិ** "ការយល់ឃើញត្រឹមត្រូវ"

ការបណ្តោយឱ្យជីវិត ចិត្ត វិញ្ញាណ អណ្តែតត្រសែតលឿនលយទៅតាមលោកិយ វិស័យ ឈ្មោះថា បណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងជ្រោះនៃសេចក្តីទុក្ខ ។ ការប្រណាំង ប្រជែង គ្នាដោយ លោភៈ ទោសៈ មោហៈ ដឹកនាំ មិនមែនជាមាគ៌ាប្រសើរទេ ។ បើគេអប់រំខ្លួនឱ្យឃើញតែខ្លួនឯង ឃើញតែប្រយោជន៍ផ្ទាល់ខ្លួននោះ សុខសន្តិភាព មិន អាចកើតមានបានឡើយ ។

មនុស្សមួយចំនួន ដែលយល់ឃើញថា " ក្នុងលោកនេះ មិនមានយុត្តិធម៌ មិនមានសេចក្ដីបរិសុទ្ធទេ មិនមានមនុស្សល្អទេ អ្នកធ្វើប្រយោជន៍ឱ្យគេសុទ្ធតែជាអ្នកប្រវញ្ចន៍ មិនមានធម៌មេត្តាករុណាទេ មិនមានសេចក្ដីពិតទេ មនុស្សទាំងអស់សុទ្ធ តែសុីគ្នា ។

សេចក្ដីយល់ឃើញដូចលើកឡើងនេះ មានន័យថា គេទុកលោកនេះជាឋាននរក ហើយគេកំពុងសាងលោកនេះឱ្យកាន់តែរស់សេចក្ដីសង្ឃឹមគ្មានទីពឹងទាល់តែសោះ ។

មនុស្សដែលមិនបានអប់រំខ្លួនក្នុងមាគ៌ាដ៏ប្រសើរ បើលឃើញសេចក្ដីអាក្រក់ របស់ខ្លួន និង សេចក្ដីអាក្រក់របស់អ្នកដទៃ ហើយកំណត់ជឿថា" អ្នកណាក៏អាក្រក់ដូចខ្លួនដែរ" ។ សេចក្ដីយល់ឃើញហ្នឹង ជាការយល់ឃើញខុសច្បាកគន្លងធម៌ ហៅថា **មិច្ឆាទិដ្ឋិ** គឺយល់ឃើញតែក្នុងសេចក្ដីងងឹតរបស់ខ្លួន ហើយទុកការយល់ឃើញ របស់ខ្លួនថាជា " សេចក្ដីពិត " មិនមានសេចក្ដីពិតណា" ក្រៅពីការយល់ឃើញរបស់ខ្លួនឡើយ ។

មនុស្សដែលមានការយល់ឃើញខុស ហៅថា មនុស្សមិច្ឆាទិដ្ឋិ បើគេមានគំនិតនេះច្រើនឡើងៗ មហាភ័យនឹងកើតឡើងដល់មនុស្សលោកនេះមិនខាន លោកនេះនឹងក្លាយទៅជាភ្លើងនរក ឥតសង្ស័យឡើយ ។

តែសេចក្ដីពិត មនុស្សលោកយើងនេះ មានសេចក្ដីសុខជាងសត្វតិរច្ឆាន ។ ព្រោះមនុស្សចេះធ្វើបច្ច័យគ្រប់គ្រាន់សម្រាប់បន្តការរស់នៅរបស់ខ្លួនទៅបាន ។ មិនត្រឹមតែប៉ុណ្ណោះទេ មនុស្សមានគ្រួសារ មានញាតិសន្តាន មានការរាប់អានស្រឡាញ់



គ្នាទៅវិញ ទៅមក ។ ផាសុកភាព គឺភាពរស់នៅសុខស្រួលនេះ កើតឡើងដោយមនុស្សធម៌ ដោយព្រហ្មវិហារធម៌ ដោយសង្គហធម៌ ។ល។ របស់មនុស្សបានខំប្រឹងប្រែងរៀបចំឱ្យបានប្រសើររៀងដរាបមក ។ ការចេះជួយគ្នា ការចេះសង្គ្រោះគ្នា ការចេះសន្តោសប្រណីគ្នា ការធ្វើឱ្យបានសេចក្ដីសុខចំរើនរបស់មនុស្សនេះកើតមកពីការយល់ត្រឹមត្រូវ ដែលហៅថា សម្មាទិដ្ឋិ នេះឯង ។ លោកអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាម្ចាស់ជាដើម តែងសរសើរថា សម្មាទិដ្ឋិ នេះជាគុណធម៌ដ៏ពិសេស បានតម្លៃកាត់មិនបាន ព្រោះគុណធម៌នេះហើយ ដែលនាំលោកនេះទៅកាន់សុខសន្តិភាព រហូតដល់បរមនិព្វាន ។

ព្រះសម្ពុទ្ធទ្រង់បានឃើញយល់ថា ក្នុងលោកនេះមានមនុស្សយល់ឃើញផ្សេងៗគ្នា ហើយទ្រង់ប្រមូលទិដ្ឋិទាំងនោះទុកជាមាតិកា មាន ៦២ ប្រការ ហៅ **ទិដ្ឋិវត្ថុ** គឺហេតុដែលនាំឱ្យបានសេចក្ដីយល់ឃើញ ។

បណ្ដាទិដ្ឋិទាំង ៦២ប្រការនេះ បើពោលដោយខ្លីមាន ២ ប្រការ គឺ :-

១- ការយល់ឃើញថាទៀង គឺ សត្វ មនុស្ស ទេវតា ស្លាប់ទៅកើតឡើងសត្វនៅជាសត្វ មនុស្សនៅជាមនុស្ស ទេវតានៅជាទេវតា ទៀងយ៉ាងនេះរហូតទៅ ហៅថា : សស្សតទិដ្ឋិ ។

២- ការយល់ឃើញថាសូន្យ គឺ មនុស្ស សត្វ ទេវតា ស្លាប់ទៅសូន្យបាត់ឈឹង មិនកើតទៀតទេ ហៅថា : ឧច្ឆេទទិដ្ឋិ ។

បើនិយាយឱ្យវែងជាងនេះបន្តិច មាន៣យ៉ាងគឺ :-

១-ការយល់ឃើញថា ការធ្វើបុណ្យ បាប ល្អ អាក្រក់ មិនបានទេ គឺមិនមានផលជាបុណ្យ ជាបាប ល្អអាក្រក់ទេ ការធ្វើល្អ អាក្រក់ គ្រាន់តែជាកិរិយា គឺមានតែកិរិយាប៉ុណ្ណោះទេ ហៅថា **អកិរិយទិដ្ឋិ** ។

២-ការយល់ឃើញថា មិនមានហេតុដែលជា បុណ្យ បាប ល្អ អាក្រក់ទេ ហេតុដែលនាំឱ្យកើត បុណ្យ បាប ល្អ អាក្រក់ មិនបានទេ នេះហៅថា :- អហេតុកទិដ្ឋិ ។

៣-ការយល់ឃើញថា ផលមិនកើតទេ គឺការជិតសោធផលដែលកើតពីការធ្វើដោយ កាយ វាចា ចិត្ត ថាមិនមានទេ នេះហៅថា នត្ថិកទិដ្ឋិ ។

ការរៀបរាប់ពីទិដ្ឋិ ដោយពិស្តារមាននៅក្នុងព្រហ្មជាលសូត្រ ពម្ពីទីឃនិកាយ ។

មិច្ឆាទិដ្ឋិការយល់ឃើញខុសនេះ ជារោគចិត្តមួយធ្ងន់ធ្ងរណាស់ បើមាននៅលើរូបនៃបុគ្គលណា បុគ្គលនោះមិនអាចរកសេចក្តីសុខ ចំរើនបានឡើយ ។

ព្រះពុទ្ធគឺជាគ្រូពេទ្យមួយដ៏ចំណាន ព្យាបាលរោគចិត្តឱ្យជាសះស្បើយបានដោយឱសថដ៏ប្រសើរ គឺ សម្មាទិដ្ឋិ "ការយល់ឃើញត្រឹមត្រូវ"។ ការយល់ត្រឹមត្រូវនេះជាមាគ៌ាដ៏ប្រសើរនៃពុទ្ធសាសនា ។

**សម្មាទិដ្ឋិ** ការយល់ឃើញត្រឹមត្រូវ បើពោលតាមបរិយាយមាន២យ៉ាងគឺ

១-**លោកិយសម្មាទិដ្ឋិ** ការយល់ឃើញត្រឹមត្រូវថ្នាក់ទាប ដូចជាការយល់ឃើញថាធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ការគោរពបំរើមាតា បិតា ជីដូន ជីតា គ្រូ អាចារ្យ ការសេពគប់បណ្ឌិត នាំឱ្យកើតបុណ្យ ឱ្យមានសេចក្តីចំរើន ការធ្វើសង្គហកិច្ចចំពោះអ្នកមានទុក្ខលំបាក នាំឱ្យបានជាមធ្យោបាយជួយរំដោះទុក្ខលំបាក



របស់មនុស្ស និង សង្គម ឬ យល់ថា ការព្យាយាមរកទ្រព្យសម្បត្តិ ព្យាយាមរៀនសូត្រ នាំឱ្យមានធនធាន មានចំណេះដឹង ការគោរពប្រតិបត្តិធម៌នាំឱ្យបានសុខ ការរួបរួមគ្នា ក្នុងអំពើល្អនាំឱ្យមានសេចក្តីចំរើនដូច្នេះជាដើមក៏ឈ្មោះថា សម្មាទិដ្ឋិ គ្រាន់តែស្ថិតនៅថ្នាក់ទាបប៉ុណ្ណោះ តែក៏ជាបុព្វហេតុនាំឱ្យបញ្ញាញាណឈានឡើងទៅកាន់ការយល់ដឹងថ្នាក់ខ្ពស់តាមលំដាប់បាន ។

~ **ឧត្តរិមសម្មាទិដ្ឋិ** ការយល់ឃើញត្រឹមត្រូវថ្នាក់ខ្ពស់បានដល់ការយល់ច្បាស់នូវ អរិយសច្ចៈ ទាំង៤ គឺ :

១-ទុក្ខៈ ជាផលនៃតណ្ហា ដែលចង់បានឥតស្រាកស្រាន ជាផលនៃឧបាទានការប្រកាន់ជាប់ថាថា ខ្លួនជារបស់ខ្លួន ។

២-សមុទយៈ ហេតុដែលនាំឱ្យកើតទុក្ខ បានដល់តណ្ហា ៣ ប្រការ ។

៣-និរោធៈ ការរលត់ទុក្ខ ជាផលនៃបញ្ញាបដិបទា ។

៤-មគ្គៈ ផ្លូវទៅកាន់ទីរំលត់ទុក្ខ គឺការប្រតិបត្តិដើរតាមមាគ៌ាទាំង៨ប្រការដែលហៅថា :**អដ្ឋង្គិកមគ្គ** ។

លោកដែលមានសេចក្តីយល់ឃើញត្រឹមត្រូវគឺមាន សម្មាទិដ្ឋិ នេះ ទុកជាពន្លឺនៅក្នុងចិត្តដូច្នេះហើយតែងបង្អោនចិត្តឱ្យចូលទៅកាន់ផ្លូវដ៏ប្រសើរ នៃការរួចចាកទុក្ខពោលគឺ វិមុត្តិ ពិតប្រាកដ ។

ដូចពុទ្ធ ត្រាស់ថា :-

ភិក្ខុទាំងឡាយ ! ភិក្ខុក្នុងសាសនានេះដឹងថា:-

~ ញាណគឺបញ្ញាដឹងច្បាស់ក្នុងទុក្ខ

~ ញាណគឺបញ្ញាដឹងច្បាស់ក្នុងធម៌ដែលនាំឱ្យកើតទុក្ខ

~ ញាណគឺបញ្ញាដឹងច្បាស់ក្នុងធម៌ ដែលជាទីរលត់ទុក្ខ

~ ញាណគឺបញ្ញាដឹងច្បាស់ក្នុងបដិបទា ផ្លូវនាំទៅកាន់ទីរលត់ទុក្ខ ។

ភិក្ខុទាំងឡាយ! នេះតថាគត ហៅថា សម្មាទិដ្ឋិ ការយល់ឃើញត្រឹមត្រូវ។ ការយល់ឃើញត្រឹមត្រូវនេះ បានដល់ការយល់ឃើញពិតទៅតាមការពិត នូវសភាវធម៌ ទាំងពួងគឺ ការឃើញទៅតាមអរិយសច្ចធម៌ ដែលជាតួបញ្ញាដ៏ប្រសើរលើស។

បញ្ញាក្នុងទីនេះលោកចែងជា ២ គឺ

១-**អនុពោធ** បញ្ញាដែលបុគ្គលសន្សំទុកក្នុងសន្តានចិត្តមកច្រើនហើយ ។

២-**បដិវេធ** បញ្ញាដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះនូវសភាវធម៌ទាំងពួងហើយដោះខ្លួនរួចពីសេចក្តីទុក្ខគ្រប់ប្រការ (ជាបញ្ញាដែលបុគ្គលបានមកពីការប្រតិបត្តិ ដើរតាមមាគ៌ាប្រកបដោយអង្គ ៨ នេះ) ។

អរិយមគ្គទាំង ៨ ប្រការ ដូចបានសំដែងមកនេះ ជាមាគ៌ាដែលបុគ្គលម្នាក់ៗគប្បីធ្វើតាមឱ្យមានច្រើនក្នុងខន្ធសន្តាន ជាសីលធម៌សំរាប់ទូន្មាន កាយ វាចា ចិត្ត ដោយខ្លួនឯង ធ្វើឱ្យបរិសុទ្ធ ដោយខ្លួនឯង ដើម្បីបានសម្រេចនូវសេរីភាពបរិបូណ៌ បរមសុខក្សេមក្សាន្ត ដោយគុណធម៌ទាំង ៣ គឺ **សីល សមាធិ បញ្ញា** ដូចបានសំដែងមកខាងលើនេះ ។

សូមបញ្ចប់ដោយសង្ខេបត្រឹមប៉ុណ្ណោះ ។



ឯកសារមូលដ្ឋាន

~ អត្ថបទសិក្សាអរិយសច្ចបរិយាយ ព្រះភិក្ខុ ឆ៉ាន ខាត់

~ ធម្មបទអត្ថកថា

~ ធម្មចក្កប្បវត្តនសូត្រ

~ ធម្មវិភាគថ្នាក់ត្រី "ពុទ្ធសាសនបណ្ឌិត្យ

កំពង់ឆ្នាំង ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំជូត ព.ស២៥៤០ គ.ស ១៩៩៦

រៀបរៀងដោយ

ជួន ម៉េន

វាយអត្ថបទកុំព្យូទ័រដោយ លោក ឡេង ហ៊ុយ